# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០១២

## ជប៉ុនផ្តល់ ១០៣,៥៥០ ដុល្លារអាមេរិក សម្រាប់គម្រោងស្តារប្រព័ន្ធស្រោចស្រពលេខ៣៨ក្នុងខេត្តតាកែវ



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ(ជំនួយគូសាណូណេ)រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន ១០៣,៥៥០ ដុល្លារអាមេរិក ដល់មន្ទីរធនធានទឹក និងឧតុនិយមខេត្តតាកែវសម្រាប់គម្រោងស្តារប្រឡាយលេខ៣៨ក្នុងខេត្តតាកែវ។កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាដោយឯកឧត្តម គូរ៉ូគី ម៉ាសាហ៊ីមី ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា នឹងលោក ប៊ុន ហួ ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តតាកែវនៅស្ថានទូតជប៉ុន។



ជាមួយនឹងជំនួយនេះ ប្រឡាយលេខ៣៨នឹងត្រូវបានជួសជុលដោយមន្ទីរធនធានទឹក និង ឧតុនិយមខេត្តតាកែវ។គម្រោងនេះរួមបញ្ចូលការជួសជុលប្រឡាយមេប្រវែង២,១០០ម៉ែត្រ ការសាងសង់សំណង់លូចែកចាយទឹក២កន្លែង និងសំណង់ទ្វារទឹក១កន្លែង។ យើងរំពឹងថាវានឹងសម្រួលដល់ការងារស្រោចស្រពរបស់ប្រជាកសិករប្រមាណ១,៣៥៨គ្រួសារនៅក្នុងតំបន់។ ដោយមានជំនួយផ្នែកបច្ចេកទេសពីមន្ទីរធនធានទឹក និង ឧតុនិយមខេត្តតាកែវ ប្រជាសហគមន៍នឹងថែទាំប្រព័ន្ធស្រោចស្រពនេះឲ្យមានសភាពល្អជានិច្ច។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ(*ជំនួយគូសាណូណេ*) របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ និងស្តាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជាភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជិវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាល ជប៉ុនបានផ្តល់ថវិកាជាង ៤៨.១លាន ដុល្លាអាមេរិកដល់អាជ្ញាធរមូលដ្ឋាននិងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន ៤៧៩គម្រោងនៅទូទាំងប្រទេស។



---


*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*

*អ៊ីមែល: eco.jpn@.pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*